## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

-សំណុំរឿងរដ្ឋប្បវេណីលេខ ២៧២៦

ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

-សាលក្រមលេខ: ៨២៦ " ខ "

ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ និងប្រកាសនៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩ ដោយមានសមាសភាពចូលរួមដូចតទៅ:

### ចៅក្រម

លោក **រស់ សាម៉ីឌី** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជី

លោក **នៅ សុមិន** ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**ដើមចោទ៖** ឈ្មោះ ដ ភេទស្រី កើតថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៨៩ ជាតិខ្មែរ មុខរបរ រាជធានីភ្នំពេញ ។

-មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ៖ លោក **សេង សុវីណា** ។

**សហចុងចម្លើយ៖** ឈ្មោះ ច១ ភេទស្រី កើតថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៥៧ ជាតិខ្មែរ មុខរបរ និងឈ្មោះ ច២ ភេទស្រី កើតថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៨៤ ជាតិខ្មែរ មុខរបរ មានទីលំនៅបច្ចុប្បន្ន រាជធានីភ្នំពេញ ។

-មេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយ៖ លោក **វ៉ិត សុវណ្ណរ៉ា**។

**កម្មវត្ថុបណ្តឹង:** ប្តឹងសុំទាមទារប្រាក់ ។

### អង្គហេតុ និងចំណុចវិវាទ

**ក-ការទាមទាររបស់ដើមចោទ:**

១-ប្រាក់ដើមចំនួន ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក ។

២-ការប្រាក់ចំនួន ១,៨% (មួយក្បៀសប្រាំបីភាគរយ) ក្នុងមួយខែ គិតពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ រហូតដល់ថ្ងៃសងប្រាក់ដើមរួចរាល់ ។

៣-សំណងការខូចខាត និងប្រាក់ជម្ងឺចិត្តចំនួន ៣០% លើប្រាក់ដើម ។

៤-សុំវិធានការអនុវត្តបណ្តោះអាសន្នដោយបង្ខំលើប្រាក់ដើម ។

៥-សុំឱ្យទទួលបន្ទុកលើប្រាក់ពន្ធបណ្តឹង និងប្រាក់ប្រដាប់ក្តី ។

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

**ខ-ការពន្យល់ត្រួសៗអំពីរឿងក្តី:**

សហចុងចម្លើយឈ្មោះ ច១ រឈ្មោះ ច២ បានខ្ចីប្រាក់ពីដើមចោទឈ្មោះ ដ ចំនួន **៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក** ដោយបង់ការប្រាក់ចំនួន ១,៨ % (មួយក្បៀសប្រាំបីភាគរយ) ក្នុងមួយខែ ព្រមទាំងបានដាក់ ដី-ផ្ទះទំហំ ៦៨ម² ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ
ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ ដើម្បីជាការធានា ដូចមានក្នុងកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៦ ដោយកិច្ចសន្យានេះមានរយៈពេល ០៦ (ប្រាំមួយ) ខែ ។ លុះដល់ថ្ងៃកំណត់សងប្រាក់សហចុងចម្លើយពុំបានសងប្រាក់ដើមមកដើមចោទដូចមានក្នុងកិច្ចសន្យានោះទេ គ្រាន់តែបង់ការប្រាក់ជាបន្តបន្ទាប់រហូតដល់ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ សហចុងចម្លើយបានឈប់បង់ការប្រាក់រហូតមកដល់បច្ចុប្បន្ន ។

**គ-ការអះអាងរបស់ដើមចោទ:**

លោក **សេង សុវីណា** ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ ដ បានធ្វើសេចក្តីថ្លែងការណ៍ថា៖ សហចុងចម្លើយឈ្មោះ ច១ និងឈ្មោះ ច២ បានខ្ចីប្រាក់កូនក្តីខ្លួនចំនួន ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក ដោយមានរយៈពេល ០៦ខែ ក្នុងអត្រាការប្រាក់ចំនួន ១,៨% (មួយក្បៀសប្រាំបីភាគរយ) ក្នុងមួយខែ ហើយដើម្បីជាការធានាលើប្រាក់កម្ចីនេះ សហចុងចម្លើយបានយកដីផ្ទះទំហំ ៦៨ម៉ែត្រការ៉េ ស្ថិតនៅក្បាលដីលេខ ៦១ ភូមិ២១ សង្កាត់ ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញមកដាក់តម្កល់ធានាត្រូវបានចុះបន្ទុកតាមកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែត ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៦ នៅមន្ទីរសុរិយោដីរាជធានីភ្នំពេញ ដូចមានក្នុងកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៦ ។ សហចុងចម្លើយត្រូវបង្វិលសងប្រាក់ដើមទាំងអស់នៅថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០១៦ ប៉ុន្តែសហចុងចម្លើយពុំបានសងប្រាក់ដើមតាមកិច្ចសន្យាខ្ចីប្រាក់នោះទេ និងខកខានបង់ការប្រាក់ចាប់ពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ មកទល់បច្ចុប្បន្ន ហេតុនេះកូនក្តីខ្លួនស្នើសុំឱ្យតុលាការសម្រេច តាមការទាមទារខាងលើនេះ ។

**ឃ-ការអះអាងរបស់សហចុងចម្លើយ**

លោក **វ៉ុត សុវណ្ណារ៉ា** បានមេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយឈ្មោះ ច១ និងឈ្មោះ ច២ បានធ្វើសេចក្តីថ្លែងការណ៍ថា: កូនក្តីខ្លួនសូមទទួលស្គាល់ថាពិតជាបានខ្ចីប្រាក់ពីដើមចោទចំនួន ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក ។ កូនក្តីខ្លួនសូមចរចារសុំសងប្រាក់ដើមជាមួយដើមចោទចំនួន ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក, ចំពោះការប្រាក់ ១,៨% ក្នុង ០១ខែ លើប្រាក់ដើម គិតពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ រហូតដល់ថ្ងៃសងប្រាក់ដើមរួច, សំណងការខូចខាត និងប្រាក់ជម្ងឺចិត្តចំនួន ៣០% លើប្រាក់ដើម, សុំវិធានការអនុវត្តបណ្តោះអាសន្នដោយបង្កក់លើប្រាក់ដើម, សុំឱ្យទទួលបន្ទុកលើប្រាក់ពន្ធបណ្តឹង និងប្រាក់ប្រដាប់ក្តី កូនក្តីខ្ញុំបាទសូមឱ្យដើមចោទលះបង់ការទាមទារ ដោយហេតុថាកូនក្តីខ្លួនពុំមានលទ្ធភាពក្នុងការសងការប្រាក់ និងប្រាក់ជម្ងឺចិត្តនោះទេ ម្យ៉ាងវិញទៀតកូនក្តីខ្លួនចាស់ជរាពុំមានប្រាក់ចំណូល ហើយកន្លងមកកូនក្តីខ្លួនបានបង់ការប្រាក់ជូនដើមចោទបានរយៈ

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

២.៣-ឱ្យសហចុងចម្លើយសងសំណងការខូចខាត និងប្រាក់ជម្ងឺចិត្តចំនួន ៣០% លើប្រាក់ដើម តុលាការនឹងធ្វើការពិចារណាឱ្យសមស្របតាមមាត្រា ៤០០ និងមាត្រា ៤០១ នៃក្រមរដ្ឋប្បវេណី

៣-ដើមចោទបានស្នើសុំឱ្យតុលាការប្រកាសអនុវត្តបណ្តោះអាសន្នលើប្រាក់ដើម តុលាការនឹងពិចារណាសម្រេច តាមមាត្រា ១៩៦ និងមាត្រា ១៩៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

៤-ចំពោះប្រាក់ប្រដាប់ក្តីតុលាការនឹងសម្រេចឱ្យអ្នកចាញ់ក្តីជាអ្នកទទួលបន្ទុក តាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សេចក្តីសម្រេចបញ្ចប់

១-ឱ្យសហចុងចម្លើយឈ្មោះ ច១ និងឈ្មោះ ច២ សងប្រាក់ដើមចំ ដ ០០០ (បីម៉ឺន) **ដុល្លារអាមេ** ច១ ដើមចោទ ច ដ ។

២-ឱ្យចុងចម្លើយឈ្មោះ ច១ និងឈ្មោះ ច២ សងការប្រាក់ **១,៥%** **(មួយក្បៀសប្រាំភាគរយ)** ក្នុងមួយខែ លើប្រាក់ដើមចំនួន ៣០.០០០ **(បីម៉ឺន) ដុល្លារអាមេរិក** គិតពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ រហូតដល់ថ្ងៃដែលសងគ្រប់ចំនួន ទៅដើមចោទឈ្មោះ ដ ។

៣-ឱ្យសហចុងចម្លើយឈ្មោះ ច១ និងឈ្មោះ ច២ សងសំណងការខូចខាត និងប្រាក់ជំងឺចិត្តចំនួន ៣០% **(សាមសិប) ភាគរយ** លើប្រាក់ដើម ទៅដើមចោទឈ្មោះ ដ ។

៤-ប្រកាសឱ្យអនុវត្តបណ្តោះអាសន្នលើសំណងប្រាក់ដើមត្រង់ចំណុចទី **១** នៃសេចក្តីសម្រេចខាងលើ ។

៥-ឱ្យសហចុងចម្លើយទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តី ។

សាលក្រមនេះ បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ជាសាធារណៈ នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ និងប្រកាសនៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩ ចំពោះមុខមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ និងមេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយ ។

បើកផ្លូវឱ្យប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ចៅក្រម**

ហត្ថលេខា និងត្រា: **រស់ សាម៉ុឌី**

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ២កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ,ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

នៅ_សុបិន

បានឃើញ

**ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ**

**រស់ សាម៉ុឌី**